# បទល្មើស

# ទំលោភសេពសន្ថវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ១២១/២៦-០២-២០០៣

សាលដីកា

លេខៈ១២១(ជ)/២៧-១២-២០០៧

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខៈ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជា សាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧-១២-២០០៧ ដែលមានសមាសភាពដូចតទៅៈ

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ១២១ ចុះថ្ងៃទី២៦-០២-២០០៣ រវាងៈ

-ជនជាប់ចោទឈ្មោះ [redacted] ធឿន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករឡឥដ្ឋ កើតនៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃ [redacted] ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៥នាក់ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី១១.៥.២០០២ ឃុំខ្លួនថ្ងៃទី១៤.៥.២០០២។បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល។

ត្រូវចោទពីបទៈរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១១-៥-២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

មេធាវីការពារលោក [redacted] ស៊ីថាន់

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុឃឿន (ជនរងគ្រោះ) ជាកូនបង្កើតរបស់ជនល្មើស ។

១០៣

## ៦រឿងហេតុមានដូចតទៅ

ថ្ងៃកើតហេតុឈ្មោះ [redacted] ធឿន ចាប់បង្ខំរំលោភមកលើកូនរបស់ខ្លួនបង្កើតបានសម្រេចជាច្រើនលើក ហើយតែងតែប្រើអំពើហឹង្សាវាយដំមកលើជនរងគ្រោះ ។ លុះថ្ងៃទី១១.៥.២០០២ ម៉ោង៤ទៀបភ្លឺឈ្មោះ[redacted] ធឿន បានដាស់ជនរងគ្រោះដែលកំពុងដេកក្នុងផ្ទះខ្លួន ឲ្យចេញទៅក្រៅជាមួយ ដោយជនល្មើសមានកាន់កាំបិតខ្វែវមួយ ហើយនាំជនរងគ្រោះទៅទិសខាងកើតឡូតឆ្ល ចំងាយប្រហែល១០០ម ត្រង់ចំការចេក ពេលនោះជនល្មើសក៏ចាប់សម្រាតខោជនរងគ្រោះតែម្តង ហើយក៏រំលោភដោយឈររហូតបានសម្រេច ពេលរំលោភហើយក៏ឲ្យជនរងគ្រោះមកផ្ទះមុន ។ ថ្ងៃទី១១.៥.២០០២ ម៉ោង៧ព្រឹក ជនរងគ្រោះក៏ប្តឹងនគរបាលប៉ុស្តិ៍រកាកោង១ ពីឈ្មោះ[redacted]ធឿន ដែលជាឪពុកបង្កើតពីបទរំលោភ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ៣០(គ) ចុះថ្ងៃទី១១-៩-២០០២ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ[redacted]ធឿន(ឃុំខ្លួន) ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន១១.៥.២០០២ ពីបទៈរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១១-៥-២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥.៩.២០០២ ចំពោះមុខជនជាប់ចោទ និង ជនរងគ្រោះ បើកផ្លូវប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី១៦-១០-២០០៧ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាសង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ធឿន (អវត្តមាន)

-មេធាវីការពារលោក[redacted] ស៊ីថាន់ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សុឃឿន (អវត្តមាន)

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ តាមអង្គហេតុជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន សូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៣០(គ) ចុះថ្ងៃទី១១-៩-២០០២ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។

១០៤

-មេធាវីលោក [redacted] ស៊ីថាន់ សន្និដ្ឋានថា: ក្នុងរឿងនេះខ្លួនជាមេធាវីការពារជនជាប់ចោទ សូមពិនិត្យលើចម្លើយសាក្សី ព្រោះនាងធ្លាប់មានប្ដី សូមតុលាការពិចារណាលើកោសល្យវិច័យ ។ សំណូមពរសូមឱ្យតុលាការលើកលែងទោសដល់កូនក្ដីខ្លួន ។

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាឧទ្ធរណ៍</u>
## <u>យល់ឃើញថា៖</u>

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៧.១០.២០០២ របស់ជនជាប់ចោទ [redacted] ធឿន ធ្វើឡើងក្នុងកំណត់ច្បាប់ដោយស្របតាមបញ្ញត្តិមាត្រា១៧៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២-លិខិតលេខ:៧៩១/គម/០៧ ចុះថ្ងៃទី៧.១២.២០០៧ របស់គណៈមេធាវី ចាត់មេធាវី [redacted] ស៊ីថាន់ ជាមេធាវីការពារក្ដីឱ្យជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-អំពើប្រព្រឹត្តរបស់ជនជាប់ចោទដូចជា លួកលេងប្រដាប់ភេទកូនស្រីឯងនៅកន្លែងធ្វើការឡូតឌូ ការនាំកូនស្រីទៅជីកត្រពាំង ឬកាប់ចេក ផ្ទុះត្រី ផ្ទុះកង្កែបពេលយប់ និងការអង្វររបស់ជនរងគ្រោះឱ្យអ្នកជិតខាងជួយកុំឱ្យឪពុកប្រព្រឹត្តមកលើខ្លួន ទាំងអស់នេះជាភស្ដុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ធឿន ពីបទរំលោភសេពសន្ថវៈលើកូនខ្លួនឯង ។

៤-សាលក្រមព្រហ្មទណ្ឌលេខ:៣០(គ) ចុះថ្ងៃទី១១-៩-២០០២ របស់សាលាដំបូងខេត្តកណ្ដាល មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

## <u>ហេតុដូច្នេះ</u>
## <u>វិនិច្ឆ័យសេចក្ដី</u>

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៧.១០.២០០៧ របស់ជនជាប់ចោទ [redacted] ធឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយខ្វះអង្គច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៣០(គ) ចុះថ្ងៃទី១១-៩-២០០២ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល ។

៣-បន្តការឃុំខ្លួនជនជាប់ចោទ [redacted] ធឿន តាមនីតិវិធី ។

១០៥

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹង ។

បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី១៦ ខែ៣ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]